អនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ហត្ថលេខា
គាត ឈន់
ទេសរដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

***

## អនុក្រឹត្យលេខ ៨៨ អនក្រ.បក
## ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី សំរាប់ជំនួយការ ក្នុងការប្រតិបត្តិបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងវិស័យដីធ្លី ។ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានទីតាំងស្ថិតនៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

### ជំពូកទី ២

### បេសកកម្ម និង សមាសភាព

**មាត្រា ២ .-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានបេសកកម្មផ្តួចផ្តើមជំរុញដាក់អោយដំណើរការ និងតាមដានការអនុវត្តន៍គោលនយោបាយ និងកម្មវិធីការងារដីធ្លី ស្របតាមការតម្រង់ទិសរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៣ .-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានមុខងារ និងភារកិច្ចដូចតទៅ :

១-ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងផែនការកម្មវិធីការងារ និងយុទ្ធសាស្ត្រសំរាប់ធ្វើអោយសំរេចគោលដៅទាំងឡាយនៃការរៀបចំ ការគ្រប់គ្រង និងការបែងចែកដីធ្លី ។

២-អនុវត្តសេចក្តីណែនាំដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការយុទ្ធសាស្ត្រ និង កម្មវិធីការងារដីធ្លី ។

៣-ចេញសេចក្តីសំរេច និងសេចក្តីណែនាំដល់ ក្រសួង ស្ថាប័ន ខេត្ត ក្រុង ក្នុងការដាក់អោយដំណើរការកម្មវិធីការងារដីធ្លីក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

៤-សំរបសំរួលសកម្មភាពនានារបស់ក្រសួង ស្ថាប័នទាំងឡាយដែលទាក់ទងទៅនឹងកម្មវិធីការងារដីធ្លី ។

៥-លើកសំណើគោលនយោបាយដីធ្លី ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ដើម្បីសុំការសំរេច ។

៦-លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងច្បាប់ លិខិតបទដ្ឋាន និងវិធានការទាំងឡាយដែលទាក់ទងនឹងកិច្ចដំណើរការការងារដីធ្លី ។

៧-សំរបសំរួលមធ្យោបាយរបស់រដ្ឋ និងជំនួយអន្តរជាតិសំរាប់ប្រើប្រាស់ ក្នុងការងារដីធ្លី ។

៨-ដឹកនាំ និងគ្រប់គ្រងការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី ។

៩-ធ្វើរបាយការណ៍ជាប្រចាំជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋអំពីលទ្ធផលនៃការងារដីធ្លី ។

**មាត្រា ៤ .-**

ក្រុមប្រឹក្សាកំណែទម្រង់ដីធ្លី មានសមាសភាពដូចតទៅ :

| | |
|---|---|
| -រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| -រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| -រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |

-រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

| | |
|---|---|
| -រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងពត៌មាន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងផែនការ | ជាសមាជិក |
| -អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| -អគ្គលេខាធិការ នៃគណៈកម្មការវិនិយោគកម្ពុជា | ជាសមាជិក |

**មាត្រា ៥ .-**

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវ បំពេញមុខការទាំងឡាយរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានចែងក្នុងមាត្រាខាងលើ និងយកចិត្តទុកដាក់ធ្វើអោយដំណើរការការងារដីធ្លីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព

-អញ្ជើញសមាជិកចូលរួមប្រជុំ កំណត់របៀបវារៈនៃការប្រជុំនានា របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ដឹកនាំការពិភាក្សា និងចេញសេចក្តីសំរេចនានា

-អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនដែលមានសមត្ថភាពជំនាញមកចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-មានសិទ្ធិចុះហត្ថលេខាទ្វេភាគី និងពហុភាគីលើគ្រប់កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន និងគ្រប់កិច្ចសន្យា ឬអត្ថបទគតិយុត្តដែលទាក់ទងទៅនឹងការងារដីធ្លី

-មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ៦ .-**

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិលើកសំណើតែងតាំងតាមករណីចាំបាច់ អ្នកជំនាញការជាតិ និងអន្តរជាតិ ហើយនិងឥស្សរជន ឬមន្ត្រីរាជការជាន់ខ្ពស់ ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាលបច្ចេកទេស ជាទីប្រឹក្សាបច្ចេកទេស ដើម្បីសិក្សាវិភាគ ធ្វើទស្សនទាន ឬផែនការកម្មលើការងារដីធ្លី និងលើកសំណើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី នូវគំរោងការងារ ដីធ្លីដែលត្រូវដាក់អោយអនុវត្ត ។

## ជំពូកទី ៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៧ .-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

អគ្គលេខាធិការមាន អគ្គលេខាធិការរង និងទីប្រឹក្សាជាជំនួយការ ។ អគ្គលេខាធិការរង និងទីប្រឹក្សាត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការ ដោយមានមតិយល់ព្រមពីប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ៨ .-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ៩ .-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់គ្រារបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញការងាររបស់ខ្លួន ។

## ជំពូកទី ៤

## ថវិកាធនធាន

**មាត្រា ១០ .-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ១១ ._

ធនធាន និងថវិការបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានផ្តត់ផ្គង់ដោយ :

-វិភាគទាន នៃថវិកាជាតិ

-ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣ ._

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ស្ថាប័ន និងសមាជិកទាំងអស់ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សមាជិកអចិន្ត្រៃយ៍

ហត្ថលេខា

សុខ អាន

★★★

## អនុក្រឹត្យលេខ ៨៩ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី